# សហគមន៍ផ្សេងៗនៅតំបន់សៀមរាប–អង្គរ

ហង្ស ច័ន្ទសោភា / លឹម ស្រ៊ូ
អាប្សារអប្សរា

អត្ថបទនេះមិនមែនជាការសិក្សាលំអិតឡើយ គ្រាន់តែជាការប្រមើលមួយគ្រួសទៅលើជីវភាព របៀបរស់នៅ ព្រមទាំងការប្រាស្រ័យទាក់ទងគ្នារវាងសហគមន៍ផ្សេងៗនៅតំបន់សៀមរាប–អង្គរ។ សហគមន៍នេះលាតសន្ធឹងតាំងពីជួរភ្នំគូលែនរហូតមកដល់បឹងទន្លេសាប។ សហគមន៍នីមួយៗខុសប្លែកគ្នាទៅតាមទីតាំងភូមិសាស្ត្រ សណ្ឋានដី ដែលជាលក្ខណៈពិសេសនៃលំនៅដ្ឋានខ្លួន។ ជម្រាលដីជាទូទៅនៃតំបន់ទាំងមូលគឺចុះពីជើងមកត្បូង ឬក៏ពីឦសានមកនិរតី។ ការបែងចែកតំបន់ដូចមានខាងក្រោមនេះ ពុំមែនជាការចែកដាច់ណាត់ ឬមានព្រំដែនអ្វីច្បាស់ឡើយ គឺគ្រាន់តែធ្វើឡើងដើម្បីងាយស្រួលសិក្សាប៉ុណ្ណោះ។

## ១. តំបន់លើ

តំបន់នេះសំដៅយកភូមិមួយចំនួនលើភ្នំគូលែននិងម្តុំជើងភ្នំ។ ជាទូទៅ គេអាចគិតតាំងពីម្តុំភូមិប្រដាក រហូតដល់ស្រុកស្វាយលើ។ ភាគខាងជើងនៃតំបន់នេះគឺខ្ពង់រាបគូលែន សម្បូណ៌ដោយព្រៃឈើច្រើនប្រភេទ ដែលជាជម្រកសត្វព្រៃដ៏សំខាន់ ហើយមានអំណោយផលល្អ ដោយសារជួរភ្នំនេះជាអាងទឹកធម្មជាតិ។ គឺនៅជួរភ្នំគូលែននេះហើយដែលអូរ ឬស្ទឹងសំខាន់ៗនៃតំបន់អង្គរចាប់កំណើតឡើង។

### ក. របររកស៊ី

កសិកម្មចល័តត្រូវបានអ្នកស្រុកអនុវត្តន៍ជាយូរលង់ណាស់មកហើយ។ ទម្លាប់នៃការធ្វើស្រែនេះ គឺគេត្រូវរានព្រៃពីកន្លែងមួយទៅកន្លែងមួយ ទុកដីឲ្យទំនេមួយរយៈ ដោយមិនមានកំណត់ រួចទើបគេត្រឡប់មកធ្វើស្រែនៅលើកន្លែងចាស់វិញ។ ដើមឡើយប្រជាជនតិច ដូច្នេះកសិកម្មប្រភេទនេះមិនធ្វើឲ្យខូចលំនឹងបរិស្ថានទូទៅឡើយ។ ប៉ុន្តែបច្ចុប្បន្ននេះប្រជាជនកើនឡើងដោយសារមានអ្នកស្រុកចំណូលថ្មី ឯការរានព្រៃក៏កើនឡើងដែរ។ គ្រួសារមួយកាន់កាប់ដីសម្រាប់កសិកម្មពី១០ទៅ១៥កន្លែងក្នុងមួយឆ្នាំ។ អ្នកស្រុកកាប់ឆ្ការព្រៃនៅខែមិនា រួចដុតនៅខែមេសា ហើយចាប់ផ្តើមដាំនៅខែឧសភា។

ក្រៅពីដំណាំស្រូវមានដំណាំផ្សេងៗទៀតដូចជាចេក ល្ង ពោត សណ្តែក ម្ទេស និងដំណាំមួយចំនួនទៀតសម្រាប់ទ្រទ្រង់ជីវភាពគ្រួសាររបស់គេ។ ប៉ុន្តែដំណាំទាំងនេះ ទើបតែចាប់ផ្តើមដាំក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក ដោយសារការដោះមីនផ្តល់លទ្ធភាពឲ្យអ្នកស្រុកមានដីសម្រាប់បង្កបង្កើនផល។ មានរុក្ខជាតិហូបផ្លែជាច្រើន ដូចជាស្វាយ ក្រូច ខ្នុរ ជាពិសេសដូង។ល។ ក្រៅពីកសិផលសម្រាប់ប្រើប្រាស់ក្នុងគ្រួសា មានខ្លះទៀត

# តំបន់លើ




គេដឹកមកលក់នៅតំបន់ក្រោម។ ក្នុងភូមិអន្លង់ធំមានឡក្បឿង ដែលអាចផលិតសម្រាប់បម្រើសេចក្តីត្រូវការជាទូទៅរបស់អ្នកស្រុកនៅលើភ្នំ ប៉ុន្តែការរកស៊ីកម្រិតនោះមិនអាចចាត់ថាជាឧស្សាហកម្មបានឡើយ ត្បិតការផលិតក្បឿងអាស្រ័យទៅតាមអតិថិជនត្រូវការ បើត្រូវការច្រើនទើបគេយល់ព្រមផលិតឲ្យ ដោយសារឡនេះពុំបានដំណើរការជាប្រចាំទេ។ ក្នុងការធ្វើឡនិងផលិតក្បឿង ម្ចាស់ឡជួលជាងមកពីដំដែក ប៉ុន្តែកម្មករគេយកអ្នកស្រុកនៅលើភ្នំ ព្រោះចំណាយអស់ថវិកាតិច។ អ្នកស្រុកពុំសូវមានមធ្យោបាយធ្វើដំណើរទេ ដើម្បីទិញរបស់របរប្រើប្រាស់គេត្រូវធ្វើដំណើរដោយជើងទៅផ្សារស្រុកស្វាយលើ ឆ្លងកាត់ចម្រោកភ្នំពីមួយទៅមួយ ប្រើរយៈពេលពេញមួយថ្ងៃ។ ដោយមានការលំបាកក្នុងការធ្វើដំណើរនេះហើយ ទើបអ្នកស្រុកនៅលើខ្នងភ្នំពុំសូវធ្វើដំណើរចុះមកក្រោមទេ។ ផ្ទុយទៅវិញ អ្នករស់នៅខាងក្រោមបន្តិច ពិសេសអ្នកស្រុកបន្ទាយស្រីឡើងទៅលើភ្នំដើម្បីរកទិញអនុផលព្រៃឈើ។ ពេលគេប្រមូលបានកសិផលទាំងអម្បាលមាណនេះ គេដឹកយកមកលក់បន្តនៅក្នុងភូមិ ឬចុះមកផ្សារសៀមរាប ដោយសារគេមានមធ្យោបាយក្នុងការដឹកជញ្ជូនដោយប្រើម៉ូតូ គោយន្ត ឬរ៉ឺម៉ក។

នៅលើភ្នំ មានអ្នកសៀមរាបឡើងទៅប្រកបរបរលក់ដូរ ថតរូប រត់ម៉ូតូឌុប។ ជាធម្មតា អ្នកថតរូបពេលល្ងាចចុះមកសៀមរាបវិញ ចំណែកអ្នករត់ម៉ូតូឌុប មួយខែទើបចុះមកសៀមរាបម្តង។ អ្នករត់ម៉ូតូឌុបភាគច្រើនជាអតីតទាហាន ដែលធ្លាប់ធ្វើការនៅតំបន់នោះ ចំណែកអ្នកឯទៀតខ្លះមកពីភូមិអន្លង់ធំ និងថ្មដ្រូញ។ កាលពីសម័យមុនសង្គ្រាម ផលកសិកម្មរបស់អ្នកនៅលើខ្នងភ្នំប្រសើរជាងនៅតំបន់ក្រោម ដោយសារធម្មជាតិអំណោយផល ហើយផលទាំងនោះអាចនាំទៅកាន់ខេត្តផ្សេងៗទៀតផង[៦]។

---

[៦] Jean Boulbet, *Le Phnom Kulen et sa région*, EFEO, Paris 1979, p.79-99.

នៅក្បែរជើងភ្នំ មានអ្នកស្រុកខ្លះដែលជាអ្នកចំណូលថ្មី ដូចជាអ្នកស្រុកមកពីកំពង់ឃ្លាំង, កំពង់ក្ដី, ដំដែក, ពុំមានប្រកបរបរដើរព្រៃទេ។ គេចូលចិត្តប្រកបរបរដាំដំណាំដូចជាបន្លែគ្រប់មុខ មានស្ពៃ ត្រឡាច ឪឡឹក ត្រសក់ សណ្ដែក ម្ទេស ក្រូច។ល។ ពេលបានផល គេយកមកលក់នៅផ្សារបន្ទាយស្រី ហើយមានអ្នកទិញបន្តដឹកមកលក់នៅសៀមរាប។ មូលហេតុដែលអ្នកស្រុកតំបន់ក្រោមមករស់នៅដើម្បីដាំចំការ ព្រោះដីនៅតំបន់នេះធ្វើចំការបានទិន្នផលខ្ពស់។

អ្នករស់នៅម្ដុំភូមិប្រដាកមានរបរច្រើន ដូចជាធ្វើស្ករត្នោត ដោយសារភូមិរបស់គេនេះសម្បូណ៌ដោយដើមត្នោត។ គ្រួសារខ្លះប្រកបរបរធ្វើវត្ថុអនុស្សាវរីយ៍អំពីឈើនិងឫស្សី ដើម្បីលក់ឲ្យភ្ញៀវទេសចរនៅតំបន់អង្គរ។ ក្រៅពីនេះមានរបរលក់ដូរមួយចំនួនផ្សេងទៀត ដូចជាគ្រឿងហូបចុក និងរបស់របរប្រើប្រាស់ខ្លះផង។

ចំណែកឯប្រជាជនដែលរស់នៅតាមផ្លូវទៅកាន់ប្រាសាទបន្ទាយស្រី ច្រើនប្រកបរបរច្រូតស្បូវ រួចដេរជាកណ្ដបលក់នៅតាមផ្ទះ ដោយសារមានស្បូវដុះច្រើននៅក្បែរភូមិ។ អ្នកខ្លះរកស៊ីកាប់អុស ធ្យូង ឫស្សី ដែលដុះនៅក្បែរៗភ្នំ។ នៅពេលផលិតបានហើយ គេលក់ដូរនៅក្នុងភូមិផង និងមានឈ្មួញកណ្ដាលដែលរស់នៅសៀមរាបឡើងទៅទិញបន្តយកមកលក់នៅទីរួមខេត្តផង។ អ្នកស្រុកដែលរស់នៅក្នុងស្រុកអង្គរធំ ដូចជាភូមិលាងដៃ, ភ្លង់, សំរោង, ក្រៅពីធ្វើស្រែ គេចូលព្រៃបោចវល្លិ៍ពាក់ និងផ្ដៅ ដើម្បីផលិតវត្ថុប្រើប្រាស់ផ្សេងៗដូចជា កន្ទេល ជាល កន្ត្រក។ ដោយសារការកាប់ព្រៃក្នុងបរិវេណអង្គរត្រូវហាមឃាត់ អ្នកស្រុកទៅរកវល្លិ៍នៅម្ដុំភ្នំបូក និងម្ដុំវត្តប្រី ហើយមានអ្នកខ្លះទៅរកដល់ភ្នំគូលែនទៀតផង ដោយសារនៅទីនោះសម្បូណ៌វល្លិ៍ ផ្ដៅ ពាក់។ ជាទូទៅអ្នកស្រុកនាំចេញនូវ អុស ធ្យូង កន្ទេលផ្ដៅ ជាល កន្ត្រក ផ្លែឈើព្រៃ។ល។ គេដឹកផលិតផលទាំងនោះមកលក់នៅសៀមរាបផ្ទាល់តាមកង់ឬរ៉ឺម៉ក។ ប៉ុន្តែចំពោះការនាំចេញនូវបន្លែស្រស់ និងមាន់ទា ជ្រូក គោ... មានឈ្មួញចល័តឡើងពីសៀមរាបទៅទិញតាមភូមិ។

## ខ. សិក្សាធិការ

ការរស់នៅចល័តចុះឡើងរបស់អ្នកស្រុក ជាមូលហេតុដែលក្មេងគ្មានឱកាសបានរៀនសូត្រត្រឹមត្រូវ។ សាលារៀនភាគច្រើនជាបឋមសិក្សាប៉ុណ្ណោះ។ មួយចំនួនធំនៃកុមារនៅទីនោះសិក្សាបានត្រឹមកម្រិតបឋមសិក្សា ដោយសារត្រូវជួយការងារខ្លះៗក្នុងគ្រួសារ និងចូលព្រៃតាមឪពុកម្ដាយ ដើម្បីរកផលផ្សេងៗ។ ក្មេងរស់នៅតាមភូមិនៅលើខ្នងភ្នំគូលែនស្ទើរទាំងអស់ពុំបានចូលរៀនទេ ពិសេសក្មេងៗនៅភូមិខ្លាឃ្មុំ ដោយខ្វះថ្នាក់រៀន និងសាលានៅឆ្ងាយទៀតផង។ អ្នកមានលទ្ធភាពមួយចំនួនតូចបញ្ជូនកូនឲ្យរៀនបន្តនៅអនុវិទ្យាល័យប្រដាក ក្នុងស្រុកបន្ទាយស្រី និងខ្លះទៀតឲ្យកូនចៅទៅរៀននៅសៀមរាបតែម្ដង។

## គ. សុខាភិបាល

នៅតាមទីរួមស្រុក មានមណ្ឌលសុខភាព ដូចជានៅស្រុកបន្ទាយស្រី និងស្រុកស្វាយលើ។ បរិក្ខារនិងថ្នាំពេទ្យមានការខ្វះខាត។ ចំណែកនៅតាមភូមិគ្មានមណ្ឌលសុខភាពទេ។ មានបុគ្គលិកសុខាភិបាលចុះទៅចាក់ថ្នាំបង្ការជម្ងឺ៦មុខដល់កុមារតាមភូមិ។ ប្រសិនបើមានជម្ងឺ អ្នកស្រុកភាគច្រើនព្យាបាលដោយឱសថបុរាណ និងការស្ដោះផ្លុំ។ ស្ត្រីច្រើនឆ្លងទន្លេនៅតាមផ្ទះ ដែលជាប្រពៃណីមានតាំងពីយូរយាមកហើយ។ បើមានជម្ងឺធ្ងន់ទើបគេបញ្ជូនមកមន្ទីរពេទ្យខេត្តសៀមរាប។

## ឃ. ជំនឿ និងប្រពៃណីផ្សេងៗ

អ្នកស្រុកនៅតំបន់នេះកាន់ព្រះពុទ្ធសាសនាដូចតំបន់ផ្សេងៗទៀតដែរ។ ប៉ុន្តែនៅតំបន់នេះពុំសូវសម្បូណ៌វត្តទេ ហើយវត្តដែលមានទាំងនោះ មិនសូវមានការរីកចម្រើនឡើយ ដោយសារជីវភាពប្រជាជននៅក្រខ្សត់។ ចំពោះអ្នកភូមិដែលនៅឆ្ងាយពីវត្ត គេតែងកសាងសាលាឆទាននៅក្នុងភូមិតែម្ដង ដើម្បីនិមន្តព្រះសង្ឃមកពីវត្តផ្សេងៗមកសម្ដែងធម៌ ពិសេសនៅថ្ងៃសីល និងរៀបចង្ហាន់ប្រគេនព្រះសង្ឃនៅទីនោះផ្ទាល់តែម្ដង ដូចជានៅភូមិរហាល, ភ្លង់, លាងដៃ។

ប្រជាជនមានជំនឿគោរពអ្នកតា ដែលមានឈ្មោះផ្សេងៗគ្នា។ ជាទូទៅ នៅតាមភូមិនីមួយៗមានខ្ទមអ្នកតាស្ថិតនៅទីទួលក្រោមដើម

ឈើធំៗ។ រៀងរាល់ឆ្នាំ គេធ្វើពិធីបុណ្យឡើងអ្នកតាប្រចាំភូមិ ដែលមានអ្នកស្រុកនៅភូមិនោះជាអ្នករៀបចំ ដើម្បីសុំសេចក្ដីសុខចម្រើន។ ចំណែកអ្នករស់នៅលើខ្នងភ្នំនាំគ្នាប្រារព្ធពិធីបុណ្យឡើងអ្នកតា "នៅប្រាសាទអ្នកតា" តែម្ដង។

## ២. តំបន់កណ្ដាល

តំបន់នេះសំដៅទៅលើប្រជាជនរស់នៅក្រុងសៀមរាប។ ក្រុងនេះដើមឡើយគ្រាន់តែជាទីប្រជុំនៃភូមិមួយចំនួនធំ ដែលរាយជាប់គ្នាជាពិសេសតាមដងស្ទឹង។ ភូមិនីមួយៗមានវត្តជាគោល ដែលមាននាទីជាកន្លែងប្រតិបត្តិសាសនា កន្លែងអប់រំបណ្ដុះបណ្ដាលជំនាញ...។ សហគមន៍នីមួយៗច្រើនរស់នៅតាមបណ្ដោយស្ទឹងសៀមរាប លាតសន្ធឹងពីជើងទៅត្បូង តាមផ្លូវជាតិនិងតាមបណ្ដោយផ្លូវថ្មីដែលទើបនឹងកសាងមួយចំនួន។ តំបន់នេះជាទីប្រជុំជនធំជាងគេបង្អស់ ក្នុងចំណោមសហគមន៍ផ្សេងៗនៅតំបន់សៀមរាប-អង្គរ ហើយជាស្នូលនៃសេដ្ឋកិច្ច ជាបណ្ដាញនៃប្រព័ន្ធគមនាគមន៍សម្រាប់ប្រាស្រ័យទាក់ទងទៅតំបន់ផ្សេងៗក្នុងខេត្ត និងខេត្តដទៃទៀតផង។ តំបន់កណ្ដាលជាមណ្ឌលមួយដែលមានភាពរីកចម្រើនគួរសមក្នុងវិស័យជំនួញ។ គេឃើញមានផ្សារធំៗពីរ គឺផ្សារលើ និងផ្សារចាស់ ហើយព្រមទាំងមានហាងទំនិញជាច្រើនប្រមូលផ្ដុំគ្នា។ នៅតាមបណ្ដោយដងផ្លូវធំ មានមនុស្សអ៊ូអរតាំងពីព្រលឹមស្រាងៗ រហូតដល់ព្រលប់ ប្រាស្រ័យទាក់ទងគ្នាក្នុងរបរចិញ្ចឹមជីវិត។ ម្យ៉ាងទៀតទីនេះជាកន្លែងប្រមូលផ្ដុំស្ថាប័នរដ្ឋបាល ទីស្នាក់ការស្ថាប័នជាតិ អង្គការជាតិនិងអន្តរជាតិ សណ្ឋាគារ ភោជនីយដ្ឋានជាច្រើនទៀត។ល។ ដូចនេះក្រៅពីអ្នកលក់ដូរ មានប្រជាជនមួយចំនួនជាមន្ត្រីរាជការ និងធ្វើការនៅតាមក្រុមហ៊ុនឯកជន ព្រមទាំងបណ្ដាអង្គការអន្តរជាតិ។

### ក. របររកស៊ី

អ្នកលក់ដូរនៅតំបន់នេះទទួលទំនិញពីគ្រប់ទិសទី រួមមាន ឧបករណ៍និងសម្ភារៈប្រើប្រាស់មួយចំនួន ដែលគេដឹកមកពីភ្នំពេញ និងប្រទេសសៀម ព្រមទាំងបណ្ដាផលិតផលជាច្រើនផ្សេងៗទៀត ដែលមកពីគ្រប់តំបន់ផ្សេងៗក្នុងខេត្ត។ ឈ្មួញចល័តតែងតែដើរទិញកសិផល និងផលិតផលតាមភូមិផ្សេងៗ ដូចជាទិញបន្លែស្រស់ ជ្រូក មាន់ ទា និងអនុផលព្រៃឈើ។ ពេលទិញបានកសិផលទាំងនោះ គេដឹកជញ្ជូនតាមរ៉ឺម៉កម៉ូតូ និងរថយន្តមកកាន់ផ្សារសៀមរាប។ មុខរបរដែលសំខាន់មួយទៀត គឺលក់វត្ថុអនុស្សាវរីយ៍។ ការផលិតវត្ថុអនុស្សាវរីយ៍ក៏ជាមុខរបរមួយអាចរកកម្រៃបានគួរសម ដូចជាផលិតនូវរូបចម្លាក់អំពីថ្ម អំពីឈើ និងអំពីលោហធាតុ។ ដោយសារក្រុងសៀមរាបជាតំបន់ដែលអ្នកទេសចរមកស្នាក់នៅ ដើម្បីទស្សនាប្រាសាទរមណីយដ្ឋានបុរាណ ក្រុងនេះរីកដុះដាលមានបម្រើសេវាកម្មទេសចរ ដូចជាក្រុមហ៊ុនទេសចរណ៍ ផ្ទះសំណាក់ សណ្ឋាគារ ហាងលក់ដូរផ្សេងៗ និងសេវាកម្មដឹកជញ្ជូនភ្ញៀវ តាំងពីម៉ូតូរហូតដល់រថយន្តតូចធំជាច្រើនទៀត។ អ្នកខ្លះធ្វើដំណើររហូតដល់ភ្នំគូលែន និងតំបន់ក្បែរជើងភ្នំ ដើម្បីប្រាស្រ័យទាក់ទងទិញគ្រឿងស្នែងសត្វព្រៃ ស្បែកសត្វ ខ្ទឹម[២] និងរុក្ខជាតិឱសថ ។ ការធ្វើដំណើរទៅនោះ ចំណាយពេល២ទៅ៣ថ្ងៃ។ ដើម្បីងាយស្រួលដល់ការធ្វើដំណើរ ត្រូវមានទំនាក់ទំនងល្អជាមួយអ្នកស្រុកលើ ពិសេសគឺប្រធានភូមិ ដែលអាចជួយដល់ការធ្វើដំណើរពីភូមិមួយទៅភូមិមួយទៀត។

### ខ. សិក្សាធិការ

ក្រុងសៀមរាបមានសាលារៀនតាំងពីថ្នាក់មត្តេយ្យរហូតដល់ថ្នាក់វិទ្យាល័យ។ ចំណែកសាលាបឋមសិក្សាវិញមានច្រើន ស្ថិតនៅក្នុងបរិវេណវត្ត។ នៅតាមភូមិផ្សេងៗទៀតក៏មានសាលារៀនដែរ ដើម្បីបម្រើឱ្យសេចក្ដីត្រូវការចាំបាច់របស់កូនចៅប្រជាជនដែលរស់នៅតាមតំបន់នីមួយៗនោះផ្ទាល់តែម្ដង។ ក្រៅពីសាលារៀនដែលចំណុះឱ្យស្ថាប័នរដ្ឋ យើងសង្កេតឃើញមានសាលារៀនឯកជនមួយចំនួនទៀត ដូចជាសាលារៀនភាសាបរទេសដែលគ្រប់គ្រងដោយឯកជន ឬអង្គការក្រៅរដ្ឋាភិបាល។ អ្នកខ្លះទៀតបញ្ជូនកូនទៅបន្តការសិក្សានៅភ្នំពេញ សម្រាប់ថ្នាក់មហាវិទ្យាល័យ និងជំនាញផ្សេងៗ។

---

[២] តាមពិត នេះជាអាជីវកម្មខុសច្បាប់

### គ. សុខាភិបាល

មន្ទីរពេទ្យរដ្ឋ និងឯកជនមួយចំនួន ប្រមូលផ្ដុំនៅតំបន់នេះ។ ជាទូទៅ អ្នកដែលមានធនធានគ្រប់គ្រាន់ច្រើនយកអ្នកជម្ងឺទៅព្យាបាលនៅមន្ទីរពេទ្យនិងតាមពេទ្យឯកជន ប្រសិនបើជម្ងឺនោះមានអាការៈធ្ងន់។ យើងឃើញមានហាងលក់ឱសថទំនើបជាច្រើនទៀតនៅទីប្រជុំជននិងតាមបណ្ដាទីផ្សារធំៗនៃខេត្ត។ ចំណែកឯវិស័យសុខភាពនៃកុមារ មានមន្ទីពេទ្យទំនើបដែលបម្រើការយ៉ាងល្អក្នុងការថែរក្សា និងសង្គ្រោះកុមារដោយមានការជួយឧបត្ថម្ភតាមរយៈជំនួយអន្តរជាតិ។ ការឆ្លងទន្លេ ជាទូទៅច្រើននៅតាមមន្ទីរពេទ្យរដ្ឋ និងគ្លីនិកឯកជន។ ទោះបីមានអ្នកស្រុកនិយមព្យាបាលដោយវិធីពេទ្យទំនើបក៏ដោយ គេនៅប្រើប្រាស់ឱសថបុរាណសម្រាប់ព្យាបាលជម្ងឺផ្សេងៗដែរ។ ការស្វែងរករុក្ខជាតិឱសថ គឺធ្វើឡើងនៅព្រៃតំបន់ឧទ្យានអង្គរ និងភ្នំគូលែន ដែលគេជឿថាជាទីកន្លែងសក្តិសិទ្ធតាំងពីបុរាណកាលមក។

### ឃ. ជំនឿនិងប្រពៃណីផ្សេងៗ

វត្តអារាមមានការរីកចម្រើន។ វត្តនៅតំបន់ក្រុងមានដូចជាវត្តបូព៌, វត្តដំណាក់, វត្តព្រះឥន្ទកោសីយ៍, វត្តអធ្វា, វត្តពោធិលង្កា...។ តំបន់អង្គរគេចាត់ទុកជាកន្លែងពិសិដ្ឋសម្រាប់គោរពបូជាព្រះពុទ្ធសាសនា។ ដូចនេះហើយ រៀងរាល់ឆ្នាំគេរៀបចំពិធីនិមន្តព្រះសង្ឃ និងអញ្ជើញពុទ្ធបរិស័ទមកពីតំបន់ផ្សេងៗ ដើម្បីចូលរួមធ្វើតបៈធម៌ និងធ្វើបុណ្យផ្សេងៗនៅតាមវត្ត និងប្រាសាទ ពិសេសនៅក្នុងបរិវេណអង្គរធំ ដូចជាវត្តគោកធ្លក, វត្តឥន្ទទេព, វត្តព្រះសិអារ្យជាដើម។

តំបន់ក្រុងក៏ដូចជាតំបន់ដទៃទៀតដែរ ការគោរពអ្នកតាមានអ្នកភូមិនិយមជាទូទៅ។ ក្រៅពីអ្នកតាមួយចំនួន ដែលមាននៅតាមបណ្ដាភូមិផ្សេងៗនៃក្រុង នៅតាមវត្តអារាមក៏មានខ្ទមអ្នកតានៅជាមួយវត្តដែរ។ ឧទាហរណ៍អ្នកតាឃ្លាំងមឿងនៅវត្តព្រះឥន្ទ្រកោសីយ៍ ដែលមានទីតាំងនៅមុខប្រាសាទតែម្ដង។ ពិសេសជាងនេះទៅទៀត អ្នកស្រុករស់នៅតំបន់នេះមានជំនឿគោរព "តារាជ" ដែលជារូបព្រះនារាយណ៍ដៃ៨ នៅក្លោងទ្វារប្រាសាទអង្គរវត្ត។ ក្រៅពីជំនឿលើព្រះពុទ្ធសាសនានិងអ្នកតា ក៏មានជំនឿបែបចិន ដោយសារអ្នកស្រុកមួយចំនួនកាត់ចិនគោរពរហូតមក។ តែជំនឿទាំងនោះលាយឡំនិងព្រះពុទ្ធសាសនាច្រើន ព្រោះសាសនិកដែលជាកូនចៅចិនទាំងនោះក៏គោរពព្រះពុទ្ធសាសនាដែរ។

## ៣. តំបន់ជាយក្រុង

### ក. របររកស៊ី

ក្នុងតំបន់នេះ យើងរាប់បញ្ចូលនូវបណ្ដាភូមិមួយចំនួនដែលស្ថិតនៅឧទ្យានអង្គរ រួមមានភូមិដែលស្ថិតនៅជុំវិញបារាយទឹកថ្លា ភូមិដែលស្ថិតនៅបរិវេណអង្គរវត្តនិងអង្គរធំ ព្រមទាំងភូមិមួយចំនួនទៀតនៅតំបន់ជុំវិញក្រុង។ ភូមិទាំងនោះ ថ្វីត្បិតតែស្ថិតនៅជិតក្រុង ប៉ុន្តែបើយើងសង្កេតលើការរស់នៅប្រចាំថ្ងៃវិញ ឃើញថាមានលក្ខណៈជាជនបទស្រែចម្ការពិតៗ។ ក្រៅពីធ្វើស្រែ អ្នកស្រុកប្រកបរបរធ្វើស្ករត្នោត រកជ័រ រកវល្លិ៍ ធ្វើកម្មករនៅតាមការដ្ឋានជួសជុលប្រាសាទនានានៅតំបន់អង្គរ និងធ្វើជាកម្មករសំណង់នៅក្រុងសៀមរាប។ របររកស៊ីប្រជាជននៅតំបន់នេះ ខុសគ្នាពីកន្លែងមួយទៅកន្លែងមួយ។ ឧទាហរណ៍អ្នកស្រុកនៅភូមិនគរក្រៅ ភាគច្រើនធ្វើកម្មករនៅតាមការដ្ឋាននានាតាមប្រាសាទ។ ក្រៅពីធ្វើស្រែចម្ការគេមានមុខរបរពិសេសមួយទៀត គឺបិតស្រានៅផ្ទះរៀងៗខ្លួន។ អ្នកស្រុករស់នៅភូមិស្រះស្រង់ខាងជើង, ស្រះស្រង់ខាងត្បូង និងភូមិរហាលភាគច្រើនជាអ្នកផលិតវត្ថុអនុស្សាវរីយ៍ ដើម្បីលក់ឱ្យភ្ញៀវនៅតំបន់អង្គរ និងលក់ដុំឱ្យឈ្មួញមកពីសៀមរាប។ អ្នកខ្លះទៅធ្វើកម្មករជួសជុសប្រាសាទដែរ ឬរត់ម៉ូតូឌុប។ ចំណែកអ្នករស់នៅជុំវិញបារាយទឹកថ្លាច្រើនផលិតឧបករណ៍ប្រើប្រាស់អំពីផ្ដៅ រពាក់ វល្លិ៍ សម្រាប់លក់ឱ្យភ្ញៀវទេសចរក្នុងខេត្តសៀមរាបផង និងដើម្បីបោះដុំឱ្យឈ្មួញកណ្ដាលដែលយកទៅលក់នៅប៉ោយប៉ែតផង។ ដូចជាអ្នកភូមិគោកត្នោត, គោកបេង, ត្រពាំងល្ពៅ, គោកចាន់មានជំនាញធ្វើកន្ត្រក ជាល កន្ទេល។ អ្នកនៅភូមិខ្មៀនមានជំនាញធ្វើកង់ដៃ ដង្កៀប អំពីរពាក់ ឬស្សី និងអំពីត្រឡោក។ ក្រៅពីរបរដូចបានរៀបរាប់ខាងលើមានអ្នកលក់ដូរនៅតាមផ្ទះខ្លះៗ។ ប៉ុន្តែពុំមានលក្ខណៈធំដុំទេ។ ជួនកាលមានអ្នកដឹកទំនិញលក់ដោយកង់ មានលក់គ្រឿងទេសនិងបន្លែ ហើយក៏មានអ្នកក្រុងសៀមរាបដឹកយកមកលក់ដោយម៉ូតូ ដូចជាសាច់ត្រីស្រស់ ត្រីងៀត ត្រីឆ្អើរ ។ល។ មកទីនេះដែរ។

## ក្រុង និងជាយក្រុង




ខ. សិក្សាធិការ

ភូមិមួយចំនួនមានត្រឹមសាលាបឋមសិក្សាប៉ុណ្ណោះ។ នៅពេលបន្តទៅអនុវិទ្យាល័យសិស្សត្រូវមករៀននៅទីប្រជុំស្រុក ហើយបើចង់បន្តទៅវិទ្យាល័យត្រូវចុះមករៀននៅក្រុងសៀមរាប។ អ្នកខ្លះឲ្យកូនទៅមករៀននៅសៀមរាប ដោយសារគេមានលទ្ធភាពគ្រប់គ្រាន់។ នៅតំបន់នេះសាលាបឋមសិក្សាមួយចំនួនទទួលការឧបត្ថម្ភពីអង្គការក្រៅរដ្ឋាភិបាល ដើម្បីពង្រឹងចំណេះដឹងរបស់ក្មេងនៅតាមភូមិ ហើយក៏មានបណ្ណាល័យតូចៗដែលរៀបចំឡើងដោយអង្គការ *UNV* ប្រចាំភូមិដែរ ដូចជានៅភូមិគោកត្នោត, ស្រះស្រង់, នគរក្រៅ។ល។

គ. សុខាភិបាល

មណ្ឌលសុខភាពនៅតាមភូមិគ្មានទេ ដូចនេះអ្នកភូមិមានការលំបាក នៅពេលមានជម្ងឺជាទម្ងន់។ ជាទូទៅ គេបញ្ជូនអ្នកជម្ងឺទៅមន្ទីរពេទ្យស្រុក បើសភាពជម្ងឺធ្ងន់ទើបគេបញ្ជូនទៅមន្ទីរពេទ្យខេត្តសៀមរាប។ ដូច្នេះប្រជាជននិយមព្យាបាលដោយឱសថបុរាណ និងការស្ដោះផ្លុំដោយគ្រូបុរាណដែរ។ ចំណែកស្ត្រីជាទូទៅឆ្លងទន្លេនៅតាមផ្ទះដោយមានឆ្មបប្រចាំភូមិរបស់គេជាអ្នកជួយបង្កើតផ្ទាល់ ហើយចំណាយថវិកាតិចជាងការឆ្លងទន្លេតាមមន្ទីរពេទ្យទំនើប។ ប៉ុន្តែស្ត្រីខ្លះតាមដានសុខភាពរបស់ខ្លួននៅពេលមានផ្ទៃពោះនៅតាមមណ្ឌលសុខភាព ដែលនៅមិនឆ្ងាយពីភូមិគេប៉ុន្មាន ដើម្បីចៀសវាងប្រការគ្រោះថ្នាក់ផ្សេងៗនៅពេលឆ្លងទន្លេ។

### ឃ. ជំនឿ និងប្រពៃណីផ្សេងៗ

អ្នកភូមិដែលនៅក្បែរតំបន់អង្គរ នៅថ្ងៃសីលតែងតែធ្វើដំណើរមកសម្រាកវត្ត១យប់ ដើម្បីចូលរួមសុំសីលនៅវេលាព្រឹក រួចគេនាំគ្នាត្រឡប់ទៅផ្ទះរៀងៗខ្លួនវិញ។ ប៉ុន្តែនៅតាមភូមិ គេតែងកសាងសាលាឆទាន។ នៅថ្ងៃសីល គេនិមន្តព្រះសង្ឃពីវត្តនៅក្នុងអង្គរធំមកចាន់ក្នុងភូមិនៅថ្ងៃ៨កើត ឬ៨រោចប៉ុណ្ណោះ ចំណែកថ្ងៃពេញបូណ៌មី និងបណ្តាថ្ងៃបុណ្យធំៗ ដូចជាបុណ្យចូលឆ្នាំ បុណ្យចូលវស្សា បុណ្យចេញវស្សា... គេមិននិមន្តព្រះសង្ឃទេ អ្នកភូមិត្រូវរៀបចង្ហាន់ទៅវត្តអារាមតែម្តង។ ឧទាហរណ៍នៅភូមិគោក ត្នោត មានសាលាឆទានមួយ (រូបលេខ ១)។ គេនិមន្តព្រះសង្ឃមកពីវត្តគោកធ្លកមកចាន់ក្នុងភូមិ ដែលមានអ្នកភូមិគោកត្នោត និងគោកបេង ចូលរួមជាមួយគ្នាយកចង្ហាន់មកប្រគេនព្រះសង្ឃ។ នេះបង្ហាញពីការប្រាស្រ័យទាក់ទងគ្នារវាងភូមិនិងភូមិដែលនៅជាប់គ្នា។

តាមភូមិមានអ្នកតាប្រចាំភូមិរបស់គេ ដែលគេគោរពប្រណិប័តន៍ ដើម្បីសុំសេចក្តីសុខ។ ឧទាហរណ៍នៅភូមិគោកត្នោត មានអ្នកតាមួយដែលអ្នកភូមិហៅថាតាមុខបួន ដោយសារកាលពីមុននៅទួលក្រោមដើមចំបក់ ដែលស្ថិតនៅខាងជើងនៃប្រាសាទមេបុណ្យខាងលិចមានរូបព្រះព្រហ្មមួយអង្គមានមុខបួន (ប៉ុន្តែបច្ចុប្បន្នត្រូវបានគេលួចពីកន្លែងនោះបាត់ទៅហើយ)។ អ្នកភូមិចាត់ទុករូបនោះជាអ្នកតាប្រចាំភូមិ ហើយគេប្រារព្ធពិធីឡើងអ្នកតានៅថ្ងៃ៣កើតខែមាឃរៀងរាល់ឆ្នាំ។ ចំណែកឯភូមិមួយចំនួនដែលនៅតំបន់ខាងលិចអង្គរ គេមានជំនឿគោរពព្រះភូមិ។ ក្នុងន័យនេះ គេចាត់ទុកព្រះភូមិជាស្នូលនៃភូមិដែលហៅថាផ្ចិតភូមិ[៣]។



រូបលេខ១. ភូមិ គោកត្នោត ៖ បុណ្យចន្ទសុកគិរិសុត្ត

## ៤. តំបន់ក្រោម

តំបន់នេះគឺជាបណ្តាភូមិមួយចំនួនដែលនៅជាប់បឹងទន្លេសាប ព្រមទាំងភូមិទាំងអស់ដែលនៅក្នុងបឹងទន្លេសាបតែម្តង។ អ្នកភូមិទាំងនោះស្នាក់អាស្រ័យនៅលើទឹក ហើយរស់ដោយសារទឹក។ ដូចនេះ របរដែលសំខាន់បំផុតរបស់ពួកគេគឺការនេសាទត្រី។ ទោះបីជាភូមិមានការចល័តឡើងឬចុះដោយសារទឹកស្រកនិងឡើងក៏ដោយ ក៏គេនៅតែរក្សារបរជាអ្នកនេសាទរហូតដដែល។ ការចល័តភូមិនេះ ជាទូទៅអ្នកស្រុកកំពង់ភ្លុកនិងចុងឃ្នាសតែងតែធ្វើឡើងរៀងរាល់ឆ្នាំ។ ចំណែកឯអ្នកកំពង់ឃ្លាំងគឺពុំមានការចល័តទេ ដោយសារគេមានផ្លូវទឹក ដែលអាចចូលទៅដល់បឹងទន្លេសាបតែម្តងនៅរដូវទឹកសម្រក។ រីឯអ្នកកំពង់ភ្លុកពុំមានផ្លូវទឹកចូលទៅដល់បឹងដើម្បីធ្វើការនេសាទនៅរដូវប្រាំងទេ ដូចនេះគេត្រូវរើភូមិទាំងមូលតែម្តងទៅតាមទឹក ដើម្បីធ្វើការនេសាទជាបន្តទៀត។ ការចល័តភូមិនេះមិនមែនមានន័យថា គេបោះបង់ចោលភូមិចាស់ទៅកសាងភូមិថ្មីដើម្បីរស់នៅជារៀងរហូតនោះទេ។ ជាទូទៅ ការរើនេះតែក្នុងអំឡុងរដូវទឹកសម្រកប៉ុណ្ណោះ ហើយគេនឹងរើវិលវិញនៅរដូវទឹកឡើង។ ចំណែកអ្នករស់នៅតំបន់ចុងឃ្នាស

[៣] ទិនទីណា, ឌិនផដាភា, «ភូមិបុរាណខ្លះៗនៅខាងលិចអង្គរ», និក្ខេបបទបញ្ចប់បរិញ្ញាប័ត្របុរាណវិទ្យាឆ្នាំ១៩៩៩

# តំបន់ក្រោម




ការចល័ត នៃភូមិមានពីរប្រភេទ។ មួយគឺផ្ទះដែលឡើងនិងស្រកទៅតាមទឹក ហើយមួយប្រភេទគឺការរើផ្ទះដែលនៅជាប់មាត់បឹង។ ដូចនេះទៀត នៅពេលរដូវទឹកសម្រកត្រូវរើផ្ទះទៅសង់នៅមាត់បឹង ដើម្បីរកស៊ីជាបន្តទៀត (រូបទី២, ៣)។



រូបលេខ១២. កំពង់ភ្លុកនារដូវប្រាំង



រូបលេខ១៣. កំពង់ភ្លុកនារដូវវស្សា

## ក. របររកស៊ី

### - នេសាទ

នេសាទជាលក្ខណៈគ្រួសារ៖ ប្រជាជនដែលមានជីវភាពក្រីក្រតែងតែធ្វើការនេសាទជារៀងរាល់ថ្ងៃ នៅលើតំបន់នេសាទសាធារណៈ។ តំបន់នេះមិនមែនជាតំបន់នេសាទផ្តាច់មុខរបស់ដង្ហៅឡូត៍នេសាទឡើយ។ គេអនុញ្ញាតិឲ្យប្រើឧបករណ៍នេសាទខ្នាតតូចប៉ុណ្ណោះ ដូចជា មង សំណាញ់ បង្កៃ សន្ទូច។ រីឯផលនេសាទដែលគេប្រមូលបានមកនោះ ជាប្រភេទត្រីល្អិតដែលពុំមានតម្លៃខ្ពស់ទេ។ ត្រីទាំងនោះ ក្រៅពីសម្រាប់បរិភោគប្រចាំថ្ងៃ គេក៏លក់ដូរខ្លះៗដែរ ដើម្បីដោះស្រាយ ជីវភាព។ ក្រៅពីការនេសាទត្រី ប្រជាជនខ្លះចិញ្ចឹមត្រីដើម្បីទុកលក់នៅរដូវបិទឡូត៍នេសាទដែរ។ ប្រភេទត្រីដែលគេចូលចិត្តចិញ្ចឹមមានត្រីប្រា ត្រីឆ្តោ។ ភាគច្រើនគេចូលចិត្តចិញ្ចឹមត្រីប្រា ដោយសារត្រីនោះមានអត្រាងាប់តិច ហើយស៊ីចំណីតិចជាង ត្រីឆ្តោ។

នេសាទជាទ្រង់ទ្រាយធំ៖ ការនេសាទរបៀបនេះ គឺដង្ហៅឡូត៍ជាអ្នកមានសិទ្ធិចាត់ចែងការងារផ្សេងៗ។ គេជួលកម្មករជាច្រើននាក់ឲ្យបម្រើការនៅក្នុងតំបន់នេសាទផ្តាច់មុខ ដែលគេដេញថ្លៃបានពីក្រុមជលផល។ កម្មករនេសាទមួយចំនួនជាអ្នកស្វែងរកការងារដែលមកពីតំបន់ផ្សេងៗ និងប្រជាជនក្រីក្រដែលរស់នៅក្នុងភូមិផ្ទាល់តែម្តង។ កម្មករដែលបម្រើការងារឲ្យឡូត៍នេសាទនោះមានពីរប្រភេទ។ ម្យ៉ាងជាកម្មករដែលមកស៊ីឈ្នួលត្បាញព្រួលនៅរដូវមុនបើកនេសាទមកពីតំបន់ផ្សេងៗក្នុងខេត្ត (មួយចំនួនទៀតមកពីខេត្តដទៃ) និងកម្មករមួយប្រភេទទៀតជាកម្មករសម្រាប់នេសាទតែម្តង។ ក្នុងការនេសាទដែលមានទ្រង់ទ្រាយធំបែបនេះ គេប្រើឧបករណ៍សំខាន់ៗដូចជា អួន សម្រាស់ រាំង ព្រួល ស៊ីង លប...។ល។ ផលត្រីដែលគេទទួលបានមកវិញជាប្រភេទត្រីដែលមានតម្លៃខ្ពស់ ដូចជាត្រីរ៉ស់ ត្រីឆ្តោ ត្រីតាអោន ត្រីដំរី ត្រីសណ្តាយ...។ ត្រីទាំងនោះត្រូវគេបែងចែកជាពីរប្រភេទទៀត គឺត្រីដែលអាចប្រស់ទុកបាន គេទុកដើម្បីលក់នៅរដូវបិទឡូត៍នេសាទនិងមួយប្រភេទទៀតគេបានលក់ភ្លាមៗតែម្តង។

### -របរធ្វើស្រែចម្ការ

រៀងរាល់ឆ្នាំ នៅរដូវទឹកស្រក គេតែងតែធ្វើស្រែចម្ការទៅតាមទំហំដីដែលគេបានកាន់កាប់មួយរយៈពេលមកហើយ។ ប៉ុន្តែបច្ចុប្បន្ននេះ អាជ្ញាធរពាក់ព័ន្ធបានចេញបម្រាមមិនឲ្យប្រជាជនទាំងនោះធ្វើការដាំដុះតទៅទៀតទេ ព្រោះគេត្រូវរក្សាព្រៃលិចទឹកនៅតំបន់ទន្លេសាបឲ្យមានលំនឹងឡើងវិញ។ តែគេមិនអាចហាមឃាត់ប្រជាជនមិនឲ្យធ្វើស្រែចម្ការបានទាំងអស់តែម្តងនោះទេ ទើបគេអនុញ្ញាតិឲ្យធ្វើនៅលើដីចាស់ដែលធ្លាប់ធ្វើកន្លងមក គឺមានន័យថាគេមិនអនុញ្ញាតិឲ្យកាប់ឆ្ការព្រៃលិចទឹក ដើម្បីវាតដីដាំដុះតទៅទៀតនោះទេ។ ប្រជាជនដែលធ្វើស្រែចម្ការនៅតំបន់ព្រៃលិចទឹកទាំងនោះ ភាគច្រើនពុំមែនជាអ្នករស់នៅទីនោះផ្ទាល់ទេ គឺជាអ្នករស់នៅជាប់បឹងទន្លេសាប និងអ្នកស្រុកលើទៅវិញ។ នេះដោយសារអ្នកដែលរស់នៅក្នុងបឹងទន្លេសាបនោះផ្ទាល់គេមិនសូវចាប់អារម្មណ៍នឹងរបរនេះ គេគិតតែនេសាទតែមួយមុខប៉ុណ្ណោះថាជារបរសំខាន់។

## ខ. សិក្សាធិការ

នៅតំបន់នេះ ការសិក្សារៀនសូត្រមិនសូវមានសកម្មភាពខ្លាំងក្លាទេ ដោយសារជីវភាពទូទៅមានកម្រិតទាបនៅឡើយ។ សាលារៀនមិនសូវសម្បូណ៌ ជាទូទៅថ្នាក់រៀនមានកម្រិតត្រឹមបឋមសិក្សាប៉ុណ្ណោះ ចំពោះអ្នករស់នៅផ្ទាល់លើបឹងទន្លេសាប។ ដូចនេះ បើមានកូនចៅអ្នកភូមិណាដែលចង់រៀនបន្តទៀត ត្រូវឡើងមករៀននៅលើបន្តិច ដូចជានៅដំដែក, រលួស ឬសៀមរាបតែម្តង។ ប៉ុន្តែភាគច្រើននៃកុមាររៀនបានត្រឹមថ្នាក់ទី១ ឬទី២ និងខ្លះទៀតមិនបានរៀនតែម្តង ដោយសារជាប់រវល់ជួយឪពុកម្តាយនេសាទត្រី។ ប្រសិនបើយើងប្រៀបធៀបមកតំបន់ខាងលើបឹងទន្លេសាបនោះបន្តិច កុមារខាងលើមានការរៀនសូត្របានខ្ពស់ជាងក្មេងដែលរស់នៅផ្ទាល់ក្នុងបឹងទន្លេសាប។ ការរៀនសូត្រនៅតំបន់នេះ ខុសប្លែកពីតំបន់ផ្សេងៗទៀត ដោយសារគេចាប់ផ្តើមចូលរៀននៅរដូវទឹកឡើង ព្រោះជាពេលវេលាមួយដែលគេមានការទំនេខ្លះពីការនេសាទ ហើយគេចាប់ផ្តើមឈប់សម្រាកនៅរដូវទឹកស្រក ព្រោះជារដូវគេចាប់ផ្តើមនេសាទយ៉ាងខ្លាំងក្លា ហើយជាពេលវេលាមួយ ដែលគេរើភូមិទាំងមូលចុះទៅមាត់កំពង់ផង។

## គ. សុខាភិបាល

មន្ទីរពេទ្យនៅតំបន់ក្រោមមិនអាចបម្រើសេចក្តីត្រូវការរបស់ប្រជាជនជាទូទៅគ្រប់គ្រាន់បានឡើយ។ មានតែមន្ទីរពេទ្យប្រចាំឃុំប៉ុណ្ណោះ។ រីឯសម្ភារៈបច្ចេកទេស និងឱសថមានការខ្វះខាត។ ដូចនេះអ្នកជម្ងឺធ្ងន់ធ្ងរត្រូវបញ្ជូនមកពេទ្យសៀមរាប។ ស្ត្រីភាគច្រើនឆ្លងទន្លេនៅតាមផ្ទះដោយមាន

ធ្មប់ប្រចាំភូមិ។ ប៉ុន្តែតាមមន្ទីរសុខភាពក៏មានស្ត្រីមកពិគ្រោះយោបល់ និងមកឆ្លងទន្លេដែរ។ ក្នុងការព្យាបាលជម្ងឺ គេប្រើប្រាស់ឱសថបុរាណដែលផ្សំពីរុក្ខជាតិផ្សេងៗ ដោយសារជាការព្យាបាលដែលមានភាពងាយស្រួល និងមានតម្លៃថោកជាងការព្យាបាលដោយឱសថទំនើប។

## ឃ. ជំនឿ និងប្រពៃណីផ្សេងៗ

ក្នុងវិស័យព្រះពុទ្ធសាសនា តំបន់ក្រោមមានវត្តអារាមសម្រាប់គោរពបូជា។ ជាទូទៅ ការប្រតិបត្តិផ្នែកពុទ្ធសាសនាក៏មិនខុសគ្នាពីតំបន់ផ្សេងៗទៀតនៅតំបន់អង្គរដែរ។ រាល់ពិធីបុណ្យផ្សេងៗ អ្នកស្រុកតែងតែមកគោរពបូជានៅវត្តក្នុងតំបន់របស់គេផ្ទាល់។ នៅកំពង់ឃ្លាំង មានវត្តជាច្រើន។ នៅកំពង់ភ្លុកមានវត្តរបស់តំបន់គេផ្ទាល់ និងនៅចុងឃ្នាសមានវត្តភ្នំក្រោម។ កម្រមានប្រជាជនមកធ្វើបុណ្យនៅខាងលើណាស់ ដោយសារផ្លូវឆ្ងាយមានការលំបាក។ ព្រះសង្ឃនៅតាមវត្តមួយចំនួនពុំមែនអ្នករស់នៅតំបន់នេះផ្ទាល់ទេ ប៉ុន្តែជាអ្នកដែលមកពីតំបន់មួយចំនួននៅស្រុកលើ និងនៅសៀមរាប ហើយដែលបានមកបួសរៀននៅទីនេះ។ ក្នុងរដូវចូលវស្សាម្តងៗ មានព្រះសង្ឃមួយចំនួននិមន្តមកពីស្រុកលើ និងតំបន់ផ្សេងៗទៀតមកគង់ចាំវស្សានៅទីនោះ។

ចំណែកឯជំនឿផ្សេងៗទៀតក្រៅពីពុទ្ធសាសនា គេមានជំនឿពិសេសរបស់គេ គឺមុនពេលចេញទៅនេសាទ គេតែងតែធ្វើការបន់ស្រន់ចំពោះអ្នកតានៅក្នុងភូមិ ឬមួយគេធ្វើការបន់ស្រន់នៅតាមផ្ទះរបស់គេតែម្តង ដើម្បីប្រាថ្នាជួបប្រទះសេចក្តីសុខ និងទទួលបានផលនេសាទច្រើន។ រីឯជំនឿមួយទៀតរបស់អ្នកស្រុកកំពង់ភ្លុក គឺរៀងរាល់ឆ្នាំនៅរដូវទឹកសម្រក គេតែងរើភូមិទាំងមូលចុះទៅតាមទឹកដើម្បីធ្វើការនេសាទជាបន្តទៀត។ នៅពេលរើភូមិនោះ គេសែនអ្នកតាទាំងអស់ដែលនៅក្នុងភូមិ។ ប្រពៃណីនៃការសែនអ្នកតាក្នុងភូមិនេះ គេពុំបានកំណត់ថ្ងៃណាមួយឲ្យបានច្បាស់លាស់ទេ តែច្រើនធ្វើនៅខែទឹកស្រកដល់កម្រិត ហើយតម្រូវឲ្យចំថ្ងៃសៅរ៍ទៀតផង។

កំណត់ហេតុខាងលើនេះជាការក្រឡេកមួយភ្លែតទៅលើសហគមន៍ផ្សេងៗនៅតំបន់សៀមរាប-អង្គរដូចពោលពីខាងលើមកស្រាប់។ គោលបំណងរបស់យើងខ្ញុំគឺចង់បង្ហាញពីប្រភេទជីវភាពដែលខុសគ្នាពីតំបន់មួយទៅតំបន់មួយ ព្រមទាំងទំនាក់ទំនងគ្នារវាងតំបន់ផ្សេងៗនោះ។ ទៅអនាគត ទាល់តែមានការសិក្សាលំអិតលើវិស័យពិសេសៗ លើទិដ្ឋភាពផ្សេងៗនៃសហគមន៍និមួយៗ ទើបការយល់ដឹងរបស់យើងពីអង្គរនៅសម័យបច្ចុប្បន្នមានការដុះដាលទៅមុខ។